# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៣៨៨៤ ព.ណ.ន.ជ.

## សេចក្តីណែនាំ
## ស្តីពី
## គោលការណ៍ និងនីតិវិធីសម្រាប់ការអនុវត្តការចេញវិញ្ញាបនបត្រ បញ្ជាក់ដើមកំណើតទំនិញរបស់ក្រសួងពាណិជ្ជកម្ម

ស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងនីតិវិធីអនុវត្តការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (Certificate of Origin-CO) និងយោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ក្រសួងសម្រេចដាក់ចេញនូវគោលការណ៍ និងនីតិវិធីដូចខាងក្រោម៖

### ១. ការអនុវត្តការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

នាយកដ្ឋាននាំចេញ-នាំចូល និងតំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ត្រូវមានភារកិច្ចអនុវត្តដូចខាងក្រោម៖

- ចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (CO) ស្របតាមខ្លឹមសារប្រកាសលេខ ៣១៩៨ ពណ.ខកល ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់តាមប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម និងមិនតម្រូវឱ្យចុះហត្ថលេខា និងបោះត្រាពីក្រសួងពាណិជ្ជកម្មលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (CO) ឡើយ សម្រាប់ការនាំចេញទំនិញទៅកាន់ចក្រភពអង់គ្លេស ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តទៅ
- បញ្ចូល QR Code លើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (CO) របស់ក្រសួងពាណិជ្ជកម្ម។

### ២. ការត្រួតពិនិត្យតាមដានការអនុវត្តអនុលោមភាពវិធានដើមកំណើត

នាយកដ្ឋាននាំចេញ-នាំចូល និងតំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម មានភារកិច្ចត្រួតពិនិត្យ តាមដានការអនុវត្តអនុលោមភាពវិធានដើមកំណើតទំនិញ និងនីតិវិធីប្រតិបត្តិនៃការបញ្ជាក់ដើមកំណើតទំនិញ សម្រាប់ការនាំចេញទៅកាន់ចក្រភពអង់គ្លេស។

ទទួលបានសេចក្តីណែនាំនេះ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម
- ឯកសារ កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469